ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៤២ សហវ.ប្រក.ទូហ

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៧

# ប្រកាស
## ស្តីពី
## ការផ្តល់ វិញ្ញាបនប័ត្រវិជ្ជាជីវៈ និង អាជ្ញាប័ណ្ណ ផ្នែកសេវាកម្មវាយតំលៃ និង សេវាកម្មអចលនវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការបង្កើតក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- បានឃើញ អនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបំពេញបន្ថែម និងការកែ សំរួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញ ប្រកាសលេខ ៥៨៤ សហវ.ប្រក ចុះថ្ងៃទី១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួល ការរៀបចំ និង ការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- បានឃើញតំរូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

# សម្រេច

**ប្រការ១: គោលដៅ**

ប្រកាសនេះមានគោលដៅអនុវត្តចំពោះប្រតិបត្តិការរបស់ក្រុមហ៊ុនសេវាកម្មវាយតំលៃ និងសេវាកម្មអចលនវត្ថុ ដែលធ្វើឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ២: គោលបំណង**

ប្រកាសនេះកំណត់នូវបទប្បញ្ញត្តិផ្សេងៗដែលមានគោលបំណងដូចខាងក្រោម ÷

-កែលំអ និងតំរង់ទិសដល់ក្រុមហ៊ុនទាំងអស់ដែលកំពុងធ្វើសកម្មភាព ឬមានបំណងធ្វើសកម្មភាពផ្តល់សេវាកម្មវាយតំលៃ ឬផ្តល់សេវាកម្មអចលនវត្ថុអោយអនុវត្តបានត្រឹមត្រូវស្របតាមក្រមវិជ្ជាជីវៈដើម្បីទទួលបាននូវអាជ្ញាប័ណ្ណធ្វើសេវាកម្មស្របច្បាប់ ។

-ជំរុញអោយមានការទិញ លក់ ជួល និងបញ្ចាំអចលនវត្ថុ តាមរយៈក្រុមហ៊ុនផ្តល់សេវាកម្មអចលនវត្ថុ ដើម្បីងាយស្រួលដល់ការគ្រប់គ្រង ។

-សំរួលដល់វិនិយោគិន និងប្រជាពលរដ្ឋដែលមានបំណង ទិញ លក់ ជួល ឬបញ្ចាំ អចលនវត្ថុទាំងអស់អោយទទួលបាននូវសេវា និងតំលៃនៃអចលនវត្ថុសមស្របតាមតំលៃទីផ្សារ។

-ធានានូវនិរន្តភាពសេដ្ឋកិច្ចជាតិ និងការអភិវឌ្ឍផ្នែកអចលនវត្ថុអោយស្របតាមលក្ខណៈជាតិ និងស្តង់ដារអន្តរជាតិ ។

- បង្កើនប្រាក់ចំណូលជាតិតាមរយៈការយកពន្ធអាករ និងការបង់ថ្លៃសេវាផ្សេងៗ។

**ប្រការ៣: និយមន័យ**

- **ក្រសួង** សំដៅដល់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

- **នាយកដ្ឋាន** សំដៅដល់ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

- **ការិយាល័យ** សំដៅដល់ការិយាល័យគ្រប់គ្រងការជួញដូរអចលនវត្ថុ នៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

- **អចលនវត្ថុ** សំដៅដល់ ដី សំណង់អាគារ និងសំណង់ផ្សេងៗ រួមបញ្ចូលទាំងអ្វីៗគ្រប់យ៉ាងដែលមាននៅលើ និងនៅក្រោមដី គិតទាំងវត្ថុដែលតាំងភ្ជាប់ជាអចិន្ត្រៃយ៍នៅលើដីនោះ ទោះបីជារបស់នោះកើតឡើងដោយធម្មជាតិ ឬក៏កើតឡើងដោយសិប្បនិមិត្តក៏ដោយ ។

-**វិញ្ញាបនប័ត្រវិជ្ជាជីវៈ** សំដៅដល់វិញ្ញាបនប័ត្រដែលចេញដោយក្រសួងជូនដល់រូបវ័ន្តបុគ្គលណាមួយដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីប្រកបវិជ្ជាជីវៈជាអ្នកផ្តល់សេវាកម្មវាយតំលៃ ឬជាអ្នកផ្តល់សេវាកម្មអចលនវត្ថុ។

- **អាជ្ញាប័ណ្ណ** សំដៅដល់ អាជ្ញាប័ណ្ណផ្តល់សេវាកម្មវាយតំលៃ ឬអាជ្ញាប័ណ្ណផ្តល់សេវាកម្មអចលនវត្ថុដែលចេញដោយក្រសួងជូនដល់នីតិបុគ្គលណាមួយដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

- **សេវាកម្មអចលនវត្ថុ** សំដៅដល់ សេវាកម្ម ទិញ លក់ ជួល និងបញ្ចាំ អចលនវត្ថុ ដើម្បីយកកំរៃជើងសារ ។

- **សៀវភៅបន្ទុក** សំដៅដល់សៀវភៅស្តីពីលក្ខខណ្ឌអនុវត្តវិញ្ញាបនបត្រវិជ្ជាជីវៈ និងអាជ្ញាប័ណ្ណ សំរាប់សេវាកម្មវាយតំលៃ និងសេវាកម្មអចលនវត្ថុ ។

**ប្រការ៤: ការអនុញ្ញាតធ្វើសេវាកម្ម**

អ្នកកាន់វិញ្ញាបនបត្រវិជ្ជាជីវៈ អាចឈរឈ្មោះជាតំណាងអោយក្រុមហ៊ុនសេវាកម្មវាយតំលៃអចលនវត្ថុ ឬក្រុមហ៊ុនសេវាកម្មអចលនវត្ថុក្នុងនាមជាក្រុមហ៊ុនតែមិនអាចផ្តល់សេវាកម្មនេះក្នុងលក្ខណៈជាបុគ្គលបានទេ។ ក្រុមហ៊ុនដែលអាចផ្តល់សេវាកម្មវាយតំលៃ ឬសេវាកម្មអចលនវត្ថុបាន ត្រូវមានអាជ្ញាប័ណ្ណពីក្រសួង ។

ប្រភេទវិញ្ញាបនបត្រវិជ្ជាជីវៈ និង អាជ្ញាប័ណ្ណមានដូចខាងក្រោម ÷

ក- វិញ្ញាបនបត្រវិជ្ជាជីវៈដែលត្រូវផ្តល់ជូនរូបវន្តបុគ្គលមានៈ

- វិញ្ញាបនបត្រវិជ្ជាជីវៈវាយតំលៃអចលនវត្ថុ
- វិញ្ញាបនបត្រវិជ្ជាជីវៈសេវាកម្មអចលនវត្ថុ

ខ- អាជ្ញាប័ណ្ណដែលត្រូវផ្តល់ជូនក្រុមហ៊ុនមានៈ

- អាជ្ញាប័ណ្ណសេវាកម្មវាយតំលៃអចលនវត្ថុ
- អាជ្ញាប័ណ្ណសេវាកម្មអចលនវត្ថុ
- អាជ្ញាប័ណ្ណសាខាក្រុមហ៊ុនសេវាកម្មវាយតំលៃអចលនវត្ថុ
- អាជ្ញាប័ណ្ណសាខាក្រុមហ៊ុនសេវាកម្មអចលនវត្ថុ ។

**ប្រការ៥: ការដាក់ពាក្យស្នើសុំវិញ្ញាបនបត្រវិជ្ជាជីវៈ និងអាជ្ញាប័ណ្ណ**

រូបវន្តបុគ្គលដែលកំពុងធ្វើសកម្មភាព ឬមានបំណងចង់ធ្វើសកម្មភាពជាអ្នកផ្តល់សេវាកម្មវាយតំលៃ ឬជាអ្នកផ្តល់សេវាកម្មអចលនវត្ថុ ត្រូវមកបំពេញពាក្យស្នើសុំវិញ្ញាបនបត្រវិជ្ជាជីវៈនៅនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ។

ក្រុមហ៊ុនទាំងអស់ដែលកំពុងធ្វើសកម្មភាព ឬមានបំណងធ្វើសកម្មភាពផ្តល់សេវាកម្មវាយតំលៃ ឬសេវាកម្មអចលនវត្ថុ ត្រូវមកបំពេញពាក្យស្នើសុំអាជ្ញាប័ណ្ណនៅនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ។

**ប្រការ៦: លក្ខខណ្ឌនៃការផ្តល់វិញ្ញាបនបត្រវិជ្ជាជីវៈសំរាប់បុគ្គល**

ក្រសួងនឹងផ្តល់វិញ្ញាបនបត្រវិជ្ជាជីវៈជូនរូបវន្តបុគ្គលទាំងឡាយណាដែលកំពុងធ្វើ ឬមានបំណងធ្វើជាអ្នកផ្តល់សេវាកម្មវាយតំលៃ ឬជាអ្នកផ្តល់សេវាកម្មអចលនវត្ថុ ដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម ÷

- មានអាយុចាប់ពី ២១ ឆ្នាំឡើងទៅ ។
- មិនធ្លាប់ប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌ ឬប្រព្រឹត្តិបទល្មើសហិរញ្ញវត្ថុ ឬអំពើមិនស្របច្បាប់ណាមួយដោយមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីអាជ្ញាធរមានសមត្ថកិច្ច ។
- មានប្រវត្តិល្អលើក្រមវិជ្ជាជីវៈនិងលើការគ្រប់គ្រងអាជីវកម្មជំនួញ(ចំពោះរូបវន្តបុគ្គលដែលកំពុងធ្វើសេវាកម្ម) ។

- មានកំរិតវប្បធម៌មិចាប់ពីថ្នាក់បរិញ្ញាបត្រ ឬប្រហាក់ប្រហែល ផ្នែកសេដ្ឋកិច្ច ឬពាណិជ្ជកម្ម ឬ ច្បាប់ ធុរៈកិច្ច និង សញ្ញាបត្រ ឬវិញ្ញាបនប័ត្រផ្សេងៗទៀតដែលទាក់ទងនឹងសេវាកម្មអចលនវត្ថុ ។

- មានបទពិសោធន៍ការងារពាក់ព័ន្ធទៅនឹងសេវាកម្មអចលនវត្ថុយ៉ាងតិច ៦ខែ ។

- មានសមត្ថភាពក្នុងការទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពទាំងការនិយាយ ការសរសេរ និងមានសមត្ថភាពក្នុងការរៀបចំរបាយការណ៍ដែលមានទំរង់បែបបទត្រឹមត្រូវ ។

- បានបង់ថ្លៃវិញ្ញាបនប័ត្រវិជ្ជាជីវៈដូចមានចែងក្នុងសៀវភៅបន្ទុក ។

## ប្រការ៧: តួនាទី និងភារកិច្ចរបស់អ្នកកាន់វិញ្ញាបនប័ត្រវិជ្ជាជីវៈ

អ្នកកាន់វិញ្ញាបនប័ត្រវិជ្ជាជីវៈត្រូវមានតួនាទី និងភារកិច្ចដូចតទៅ ÷

- អ្នកកាន់វិញ្ញាបនប័ត្រវិជ្ជាជីវៈវាយតំលៃអចលនវត្ថុ មិនអាចប្រកបវិជ្ជាជីវៈសេវាកម្មអចលនវត្ថុបានទេ ហើយអ្នកកាន់វិញ្ញាបនប័ត្រវិជ្ជាជីវៈសេវាកម្មអចលនវត្ថុ ក៏មិនអាចប្រកបវិជ្ជាជីវៈវាយតំលៃអចលនវត្ថុបានដែរ ។

- អ្នកកាន់វិញ្ញាបនប័ត្រវិជ្ជាជីវៈម្នាក់អាចឈរឈ្មោះជាតំណាងអោយក្រុមហ៊ុន ឬសាខាក្រុមហ៊ុនបានតែមួយគត់ ។

- មិនត្រូវផ្តល់គំនិត ឬយោបល់ណាមួយដល់អតិថិជន ក្រៅអំពីធុរៈកិច្ច និងបទពិសោធន៍វិជ្ជាជីវៈរបស់ខ្លួនឡើយ ។

- គ្មានបុគ្គលណាមួយអាចផ្តល់សេវាកម្មវាយតំលៃ ឬផ្តល់សេវាកម្មអចលនវត្ថុខុសពីឈ្មោះរបស់ខ្លួនដែលបានប្រើនៅក្នុងវិញ្ញាបនប័ត្រវិជ្ជាជីវៈនោះទេ ។

- មិនត្រូវបង្កវាទប្បដិវាទក្នុងការផ្តល់សេវាកម្មជាមួយអ្នកកាន់វិញ្ញាបនប័ត្រវិជ្ជាជីវៈដ៏ទៃទៀតឡើយ ។

- មិនត្រូវធ្វើសេចក្តីថ្លែង ឬចូលរួមក្នុងការបង្កើតឯកសារណាមួយដែលខ្លួនបានដឹងហើយថាវាជាឯកសារ ឬ សេចក្តីថ្លែងដែលនាំអោយមានការយល់ខុស ឬជាការបោកបញ្ឆោត ។

- អ្នកកាន់វិញ្ញាបនប័ត្រវិជ្ជាជីវៈមិនត្រូវបបួល ឬអូសទាញភាគីណាមួយចុះកិច្ចសន្យា ទិញ លក់ ជួល ឬ បញ្ចាំ អចលនវត្ថុណាមួយ ឬលុបចោលកិច្ចសន្យាដែលបានធ្វើកន្លងមកជាមួយភាគីផ្សេងបានទេ លើកលែងតែមានការយល់ព្រមជាលាយលក្ខអក្សរដោយភាគីទាំងពីរនោះជាមុន ។

- មិនត្រូវផ្តល់សេវាកម្មរបស់ខ្លួនដើម្បីបំរើដល់សកម្មភាពសំអាតប្រាក់ ឬបំរើផលប្រយោជន៍ដល់ភេរវករ ឬឧក្រិដ្ឋជនណាមួយឡើយ ។ ក្នុងករណីដែលសង្កេតឃើញមានសកម្មភាពនេះ សាមីជនត្រូវរាយការណ៍ជាបន្ទាន់មកក្រសួង ឬអាជ្ញាធរមានសមត្ថកិច្ច ។

- ត្រូវសិក្សាវិធាន និងការណែនាំទាំងនេះដោយប្រុងប្រយ័ត្ន ហើយប្រសិនបើមានការសង្ស័យនូវលក្ខខណ្ឌណាមួយ សូមទំនាក់ទំនងជាមួយការិយាល័យដើម្បីសុំការពន្យល់បន្ថែម ។

## ប្រការ៨: លក្ខខណ្ឌនៃការផ្តល់អាជ្ញាប័ណ្ណសំរាប់ក្រុមហ៊ុន

ក្រសួងនឹងផ្តល់អាជ្ញាប័ណ្ណជូនដល់ក្រុមហ៊ុនទាំងឡាយណាដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម ÷

- មានលក្ខន្តិកៈចុះបញ្ជីក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម ។

- មានអ្នកកាន់វិញ្ញាបនបត្រវិជ្ជាជីវៈវាយតំលៃអចលនវត្ថុ ឬអ្នកកាន់វិញ្ញាបនបត្រវិជ្ជាជីវៈសេវាកម្មអចលនវត្ថុណាម្នាក់ឈរឈ្មោះជាតំណាង។ ការផ្លាស់ប្តូរបុគ្គលដែលកាន់វិញ្ញាបនបត្រវិជ្ជាជីវៈដែលឈរឈ្មោះជាតំណាងត្រូវមានការអនុញ្ញាតពីក្រសួងជាមុន ។ ជាមួយគ្នានេះដែរ ក្រុមហ៊ុនត្រូវដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណធ្វើសេវាកម្មសំរាប់ក្រុមហ៊ុនរបស់ខ្លួនមួយច្បាប់ទៀតមកក្រសួង ដើម្បីទទួលបានអាជ្ញាប័ណ្ណធ្វើសេវាកម្មស្របច្បាប់ ។

- បានបង់ថ្លៃអាជ្ញាប័ណ្ណដូចមានចែងក្នុងសៀវភៅបន្ទុក ។

- ភ្ជាប់របាយការណ៍លំអិតលើសេវាកម្មរបស់ក្រុមហ៊ុនក្នុងរយៈពេល ០១ឆ្នាំមុន (ចំពោះក្រុមហ៊ុនកំពុងធ្វើសេវាកម្ម) ។

- ភ្ជាប់តារាងបច្ចុប្បន្នភាពតំលៃអចលនវត្ថុដែលក្រុមហ៊ុន បាន និងកំពុងអនុវត្ត (ចំពោះក្រុមហ៊ុនកំពុងធ្វើសេវាកម្ម) ។

- ភ្ជាប់តារាងបច្ចុប្បន្នភាពតំលៃសេវាកំរៃជើងសារដែលក្រុមហ៊ុនយកពីអតិថិជន ។

- ភ្ជាប់គំរូហត្ថលេខារបស់នាយកក្រុមហ៊ុន ព្រមទាំងគំរូត្រារបស់ក្រុមហ៊ុន ។

ការកំណត់លក្ខខណ្ឌផ្សេងទៀត អាចនឹងតម្រូវបន្ថែមដោយក្រសួង ។

**ប្រការ៩: តួនាទី និងភារកិច្ច របស់ក្រុមហ៊ុន ក្នុងការផ្តល់សេវាកម្ម**

ក្រុមហ៊ុន មានតួនាទី និងភារកិច្ចដូចតទៅ÷

- ត្រូវការពារ និងលើកកំពស់អត្ថប្រយោជន៍អតិថិជនរបស់ខ្លួន ហើយកាតព្វកិច្ចចំបងមួយទៀត គឺមិនត្រូវគេចវេសពីការទទួលខុសត្រូវរបស់ខ្លួនចំពោះភាគីដ៏ទៃទៀតដែលពាក់ព័ន្ធក្នុងកិច្ចការផ្តល់សេវាកម្មឡើយ ។

- ត្រូវបង្ហាញវិញ្ញាបនបត្រវិជ្ជាជីវៈ និងអាជ្ញាប័ណ្ណរបស់ក្រុមហ៊ុនជូនអតិថិជនមុនពេលចាប់ផ្តើមប្រតិបត្តិការងារ ។

- ត្រូវសរសេរជាលាយល័ក្ខអក្សរ ដើម្បីជៀសវាងការយល់ខុសពីគ្នាទៅវិញទៅមកនូវរាល់ការលើកលែងការសន្យា និងការធានាលើសេវាជាក់លាក់ណាមួយជាមួយអតិថិជន ។

- ត្រូវពិនិត្យអោយបានល្អិតល្អន់មុនពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងណាមួយដោយបញ្ជាក់ជូនទៅភាគីហត្ថលេខីអំពីការចំណាយដែលភាគីនីមួយៗត្រូវទទួលខុសត្រូវ ។

- ត្រូវផ្តល់ជូនអតិថិជននូវសេវាប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ក្នុងកំរិតស្តង់ដារនៃសមត្ថភាពទៅតាមអាជ្ញាប័ណ្ណដែលខ្លួនទទួលបាន ។

- ត្រូវផ្តល់តារាងបច្ចុប្បន្នភាពតំលៃអចលនវត្ថុដែលក្រុមហ៊ុន បាន និងកំពុងអនុវត្តតាមតំបន់នីមួយៗមកក្រសួងអោយបានរៀងរាល់ខែ ។

- ត្រូវតាមដាននូវរាល់សភាពការណ៍ដែលអាចជះឥទ្ធិពលដល់លក្ខខណ្ឌទីផ្សារបច្ចុប្បន្ន ដើម្បីផ្តល់ជាដំបូន្មានដល់អតិថិជនរបស់ខ្លួន និង/ឬដើម្បីជួយអតិថិជនក្នុងលក្ខណៈមួយដែលមានការទទួលខុសត្រូវ ។

- នៅពេលមានការស្នើសុំអោយផ្តល់យោបល់ ឬវាយតំលៃអ្វីមួយក្រុមហ៊ុនត្រូវគិត និងធ្វើការវិភាគអោយបានល្អិតល្អន់នូវរាល់កត្តាដែលអាចជះឥទ្ធិពលដល់តំលៃអចលនវត្ថុនោះមុននឹងជំរាបជូនដល់អតិថិជនរបស់ខ្លួន។

- ត្រូវធានាថា រាល់កិច្ចព្រមព្រៀងដែលពាក់ព័ន្ធទៅនឹងកិច្ចប្រតិបត្តិការអចលនវត្ថុ ត្រូវតែធ្វើឡើងជាលាយលក្ខអក្សរដោយប្រើប្រាស់ពាក្យពេចន៍ច្បាស់ៗ និងងាយយល់ព្រមទាំងមានការបញ្ជាក់អោយបានច្បាស់លាស់នូវរាល់លក្ខខណ្ឌ កាតព្វកិច្ច និងរាល់អនុសាសន៍ ដែលភាគីពាក់ព័ន្ធបានព្រមព្រៀងគ្នា ។ រាល់កិច្ចព្រមព្រៀងដែលបានពិនិត្យ និងចុះហត្ថលេខាត្រូវតែថតចំលងដើម្បីចែកជូនដល់ភាគីដែលពាក់ព័ន្ធ ។

- មិនត្រូវផ្សាយពាណិជ្ជកម្មលើអចលនវត្ថុទាំងឡាយណា ដោយគ្មានការយល់ព្រមជាលាយល័ក្ខអក្សរពីអ្នកលក់ ឬពីម្ចាស់កម្មសិទ្ធិឡើយ ។ ជាមួយគ្នានេះដែរ មិនត្រូវផ្សព្វផ្សាយ ឬដាក់តំលៃលក់អចលនវត្ថុទាំងឡាយណាអោយខុសពីតំលៃជាក់ស្តែងដោយគ្មានការយល់ព្រមពីអ្នកលក់ ឬពីម្ចាស់កម្មសិទ្ធិនោះទេ ។

- រាល់ការដាក់ផ្លាកសញ្ញាលក់ ជួល ភតិសន្យា ឬអភិវឌ្ឍន៍នៅលើអចលនវត្ថុ ឬទ្រព្យសម្បត្តិណាមួយត្រូវធ្វើឡើងដោយក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណប៉ុណ្ណោះ ។

- ត្រូវធានាថា រាល់ការបង្ហាញនៅក្នុងការផ្សាយពាណិជ្ជកម្មគឺជាការពិត ហើយរាល់ការផ្សព្វផ្សាយអំពីទ្រព្យសម្បត្តិ ឬសេវាទាំងអស់ត្រូវតែមានបញ្ជាក់ពីអត្តសញ្ញាណរបស់ក្រុមហ៊ុន និងឈ្មោះបុគ្គលដែលទទួលបានវិញ្ញាបនប័ត្រវិជ្ជាជីវៈ ។

- រាល់កិច្ចសន្យាជាមួយអ្នកលក់ ឬអ្នកទិញ ត្រូវតែកំណត់អំពីរយៈពេលនៃការផ្តល់សេវាកម្មនោះ ។

- មិនត្រូវបង្ហាញពតិមានសម្ងាត់របស់អតិថិជនខ្លួនឡើយលើកលែងតែមានការយល់ព្រមជាមុនពីអតិថិជន ឬមានការតម្រូវពីអាជ្ញាធរមានសមត្ថកិច្ច ។ ក្រុមហ៊ុនអាចបង្ហាញពតិមានសម្ងាត់បានដោយមិនបាច់មានការយល់ព្រមពីអតិថិជន ដើម្បីការពារខ្លួន ឬជួយអាជ្ញាធរក្នុងការស្រាវជ្រាវ ឬស៊ើបអង្កេតលើការប្តឹងផ្តល់ ឬការឆ្លើយដាក់ពីសំណាក់អតិថិជនដែលបានប្រព្រឹត្តិអំពើមិនសមរម្យ ឬប្រព្រឹត្តិដោយការធ្វេសប្រហែសណាមួយ ។

- មិនត្រូវធ្វើសេវាកម្មរបស់ខ្លួនដើម្បីបំរើដល់សកម្មភាពសំអាតប្រាក់ ឬបំរើផលប្រយោជន៍ដល់ភេរវករ ឬឧក្រិដ្ឋជនណាមួយឡើយ ។ ក្នុងករណីដែលសង្កេតឃើញមានសកម្មភាពនេះ សាមីជនត្រូវរាយការណ៍ជាបន្ទាន់មកក្រសួង ឬអាជ្ញាធរមានសមត្ថកិច្ច ។

### ប្រការ១០: ការបង្កើតសាខាក្រុមហ៊ុន

ក្រុមហ៊ុនមិនអាចបង្កើតសាខាបន្ថែម ឬធ្វើសេវាកម្មខុសពីទីតាំងដែលបានបញ្ជាក់នៅលើអាជ្ញាប័ណ្ណដោយគ្មានការអនុញ្ញាតជាមុនពីក្រសួងបានឡើយ ។

ការបង្កើតសាខាក្រុមហ៊ុនបន្ថែមអាចធ្វើបានលុះត្រាតែមានការអនុញ្ញាតពីក្រសួងជាមុន ហើយមានអ្នកកាន់វិញ្ញាបនប័ត្រវិជ្ជាជីវៈជាអ្នកផ្តល់សេវាកម្មវាយតំលៃ ឬជាអ្នកផ្តល់សេវាកម្មអចលនវត្ថុណាម្នាក់ឈរឈ្មោះជាតំណាង និងត្រូវបង់ថ្លៃអាជ្ញាប័ណ្ណសំរាប់សាខាក្រុមហ៊ុនសេវាកម្មវាយតំលៃ ឬសេវាកម្មអចលនវត្ថុដូចមានចែងក្នុងសៀវភៅបន្ទុក ។

### ប្រការ១១: ការផ្ទេរ វិញ្ញាបនប័ត្រវិជ្ជាជីវៈ និងអាជ្ញាប័ណ្ណ និងការផ្អាក ឬ ការបញ្ឈប់ សកម្មភាព

វិញ្ញាបនប័ត្រវិជ្ជាជីវៈ ឬអាជ្ញាប័ណ្ណមិនអាចផ្ទេរទៅអោយអ្នកផ្សេងបានឡើយ។

ក្នុងករណីផ្អាក ឬបញ្ឈប់សកម្មភាពសេវាកម្ម ក្រុមហ៊ុនត្រូវដាក់សំណើជាលាយលក្ខ័អក្សរដោយភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ ព្រមទាំងបញ្ជាក់អំពីមូលហេតុអោយបានត្រឹមត្រូវមកក្រសួងក្នុងរយៈពេល ៣០ ថ្ងៃ (សាមសិបថ្ងៃ) មុនសេវាកម្មត្រូវបានផ្អាក ឬបញ្ឈប់សកម្មភាពជាស្ថាពរ។ ក្រោយពីផ្អាក ឬបញ្ឈប់សកម្មភាព ហើយក្រុមហ៊ុនត្រូវប្រគល់អាជ្ញាប័ណ្ណនោះមកក្រសួងវិញ ។

**ប្រការ១២: សុពលភាព និងការបន្តសុពលភាព វិញ្ញាបនប័ត្រវិជ្ជាជីវៈ ឬអាជ្ញាប័ណ្ណ**

វិញ្ញាបនប័ត្រវិជ្ជាជីវៈ ឬអាជ្ញាប័ណ្ណគ្រប់ប្រភេទមានសុពលភាពរយៈពេល ០១ ឆ្នាំ (មួយឆ្នាំ) គិតចាប់ពីថ្ងៃចុះហត្ថលេខា ។ អ្នកកាន់វិញ្ញាបនប័ត្រវិជ្ជាជីវៈ ឬអាជ្ញាប័ណ្ណត្រូវដាក់ពាក្យស្នើសុំបន្តសុពលភាពអោយបាន ០២ខែ (ពីរខែ) មុនពេលវិញ្ញាបនប័ត្រវិជ្ជាជីវៈ ឬអាជ្ញាប័ណ្ណនោះអស់សុពលភាព ។

ការបន្តសុពលភាពវិញ្ញាបនប័ត្រវិជ្ជាជីវៈ ឬអាជ្ញាប័ណ្ណជាថ្មីបាន អាស្រ័យលើការប្រតិបត្តិតាមលក្ខខណ្ឌទាំងឡាយដែលមានចែងនៅក្នុងប្រកាស សៀវភៅបន្ទុក និងសេចក្តីណែនាំផ្សេងៗទៀត ដែលចេញដោយក្រសួង ។ ការសុំបន្តវិញ្ញាបនប័ត្រវិជ្ជាជីវៈ ឬអាជ្ញាប័ណ្ណ ត្រូវបង់ថ្លៃដូចមានចែងក្នុងសៀវភៅបន្ទុកសំរាប់រយៈ ០១ឆ្នាំ បន្តទៀត ។

**ប្រការ១៣: ការផាកពិន័យ**

ក្រសួងនឹងធ្វើការផាកពិន័យចំពោះក្រុមហ៊ុនទាំងឡាយណាដែលស្ថិតនៅក្នុងករណីដូចខាងក្រោមៈ

- យឺតយ៉ាវក្នុងការសុំបន្តវិញ្ញាបនប័ត្រវិជ្ជាជីវៈ ឬអាជ្ញាប័ណ្ណដើម្បីបន្តសេវាកម្ម ត្រូវផាកពិន័យទ្វេរដងបន្ថែមលើថ្លៃអាជ្ញាប័ណ្ណដូចមានចែងក្នុងសៀវភៅបន្ទុក ។

- ផ្តល់សេវាកម្មជាមួយអាជ្ញាប័ណ្ណចាស់ដែលអស់សុពលភាព ត្រូវទទួលការផាកពិន័យចំនួន ១០ដងបន្ថែមលើថ្លៃអាជ្ញាប័ណ្ណដូចមានចែងក្នុងសៀវភៅបន្ទុក ។

- មិនគោរពតាមការណែនាំរបស់ក្រសួង ដោយបង្កើតសាខាបន្ថែម ឬធ្វើសេវាកម្មខុសពីទីតាំងដែលបានបញ្ជាក់នៅលើអាជ្ញាប័ណ្ណដោយគ្មានការអនុញ្ញាតពីក្រសួងជាមុន ត្រូវទទួលការផាកពិន័យចំនួន ១០ដងបន្ថែមលើថ្លៃអាជ្ញាប័ណ្ណដូចមានចែងក្នុងសៀវភៅបន្ទុក និងត្រូវបិទអាជីវកម្មជាបន្ទាន់រហូតដល់ទទួលបានការសំរេចជាថ្មីពីក្រសួង ។

- មិនគោរពតាមការណែនាំរបស់ក្រសួងដោយផ្ទេរអាជ្ញាប័ណ្ណអោយទៅអ្នកផ្សេងត្រូវទទួលការផាកពិន័យទាំងអ្នកកាន់អាជ្ញាប័ណ្ណ និងអ្នកផ្ទេរជាទឹកប្រាក់ចំនួន ១០ដង បន្ថែមលើថ្លៃអាជ្ញាប័ណ្ណដូចមានចែងក្នុងសៀវភៅបន្ទុក ហើយការផ្ទេរនេះគឺជាអំពើខុសច្បាប់ ។

- ក្រោយពីទទួលបានការណែនាំពីក្រសួងជាលាយលក្ខ័អក្សរហើយ នៅតែប្រព្រឹត្តល្មើសទៅនឹងចំណុចណាមួយក្នុង **ប្រការ ៧ ឬប្រការ ៩** នៃប្រកាសនេះ នឹងត្រូវទទួលការផាកពិន័យដូចមានចែងក្នុងសៀវភៅបន្ទុក ។

- យឺតយ៉ាវលើការផ្តល់របាយការណ៍ប្រចាំខែ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ តាមការកំណត់ត្រូវផាកពិន័យដូចមានចែងក្នុងសៀវភៅបន្ទុក ។

ប្រាក់ផាកពិន័យដូចបានអធិប្បាយខាងលើ ត្រូវបង់ទៅរតនាគារជាតិតាមដីកាអមដែលចេញដោយនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ។ ក្នុងករណីមិនព្រមបង់ថ្លៃផាកពិន័យនេះទេ ក្រសួងនឹងចាត់វិធានការទៅតាមផ្លូវច្បាប់ជាធរមាន ។

ក្រុមហ៊ុនណាដែលផ្តល់សេវាកម្មវាយតំលៃ ឬផ្តល់សេវាកម្មអចលនវត្ថុដោយគ្មានអាជ្ញាប័ណ្ណពីក្រសួងនឹងត្រូវផាកពិន័យដូចមានចែងក្នុងសៀវភៅបន្ទុក ។

## ប្រការ១៤: ការដកហូតវិញ្ញាបនប័ត្រវិជ្ជាជីវ: ឬអាជ្ញាប័ណ្ណ

ក្រសួងមានសិទ្ធិដកហូតវិញ្ញាបនប័ត្រវិជ្ជាជីវៈឬអាជ្ញាប័ណ្ណមកវិញ នៅពេលដែលអ្នកកាន់វិញ្ញាបនប័ត្រវិជ្ជាជីវៈ ឬអាជ្ញាប័ណ្ណបានប្រព្រឹត្តដូចករណីខាងក្រោម ÷

- អ្នកកាន់វិញ្ញាបនប័ត្រវិជ្ជាជីវៈ ឬអាជ្ញាប័ណ្ណពុំបានអនុវត្តអោយបានត្រឹមត្រូវទៅតាមខ្លឹមសារនៃប្រកាស សៀវភៅបន្ទុក និងសារាចរ ព្រមទាំងលិខិតបទដ្ឋានផ្សេងៗទៀត ដែលចេញដោយក្រសួងទៅតាមដំណាក់កាលនីមួយៗ ។

- ក្រោយពីទទួលបានការណែនាំពីក្រសួងព្រមទាំងទទួលការផាកពិន័យហើយអ្នកកាន់វិញ្ញាបនប័ត្រវិជ្ជាជីវៈ ឬអាជ្ញាប័ណ្ណនៅតែប្រព្រឹត្តិល្មើសទៅនឹងលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងប្រកាសនេះ ។

- ក្រុមហ៊ុនខកខានមិនបានបំពេញកាតព្វកិច្ចហិរញ្ញវត្ថុ រួមមាន បញ្ជីស្មាមគណនេយ្យ ឬកាតព្វកិច្ចបង់ពន្ធ និងចំណូលផ្សេងៗជូនរដ្ឋចាប់ពី ០២ខែ ជាប់គ្នា ។

- ករណីក្រុមហ៊ុនក្ស័យធនក្នុងការធ្វើសេវាកម្ម ឬប្រព្រឹត្តិល្មើសក្នុងការធ្វើសេវាកម្មណាមួយ ។

- ក្រោយពីធ្វើសវនកម្មទៅឃើញថា មានការខុសគ្នាធំដុំណាមួយរវាងរបាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំដែលបានដាក់ជូនមកក្រសួងនៅដំណាក់កាលនីមួយៗ ។

- អ្នកកាន់វិញ្ញាបនប័ត្រវិជ្ជាជីវៈ ឬ អាជ្ញាប័ណ្ណបានប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌ ឬ ប្រព្រឹត្តិបទល្មើសហិរញ្ញវត្ថុ ឬអំពើមិនស្របច្បាប់ណាមួយដែលមានភស្តុតាងច្បាស់លាស់ពីអាជ្ញាធរមានសមត្ថកិច្ច ហើយដែលក្រសួងយល់ថា មិនសមស្របជាអ្នកកាន់វិញ្ញាបនប័ត្រវិជ្ជាជីវៈ ឬអាជ្ញាប័ណ្ណ ។

- ប្រសិនបើរកឃើញថា អ្នកកាន់វិញ្ញាបនប័ត្រវិជ្ជាជីវៈ ឬអាជ្ញាប័ណ្ណបានប្រព្រឹត្តិល្មើសទៅនឹងចំណុច ទី ៨ នៃ **ប្រការ ៧** ឬ ចំណុច ទី ១៥ នៃ **ប្រការ ៩** ក្រសួងនឹងដកហូតអាជ្ញាប័ណ្ណ ព្រមទាំងចាត់វិធានការទៅតាមផ្លូវច្បាប់ជាធរមាន ។

## ប្រការ១៥: របាយការណ៍ប្រចាំខែ

ក្រុមហ៊ុនត្រូវផ្តល់ស្ថិតិ និងរបាយការណ៍សេវាកម្មប្រចាំខែមកក្រសួងមិនអោយលើសពី ១៥ថ្ងៃ នៃខែបន្ទាប់ ។ ស្ថិតិ និងរបាយការណ៍នេះត្រូវបញ្ជាក់ថា ពិត និងត្រឹមត្រូវដោយប្រធានក្រុមហ៊ុន ឬអ្នកតំណាងណាម្នាក់ដែលក្រុមហ៊ុនផ្តល់សិទ្ធិ ។

**ប្រការ១៦: របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ**

ក្នុងរយៈពេល ៣ខែ ក្រោយពីបញ្ចប់ឆ្នាំនីមួយៗ ក្រុមហ៊ុនត្រូវផ្តល់អោយក្រសួងនូវរបាយការណ៍ហិរញ្ញវត្ថុនៃឆ្នាំសារពើពន្ធកន្លងមក ដែលត្រូវបានត្រួតពិនិត្យដោយស្នងការគណនេយ្យឯករាជ្យណាមួយ ដែលមានការទទួលស្គាល់ពីក្រសួង ។

**ប្រការ១៧: ការត្រួតពិនិត្យបញ្ជី**

ក្រសួងអាចចាត់មន្ត្រីជំនាញ ដើម្បីចុះត្រួតពិនិត្យបញ្ជីគណនេយ្យ និងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងការធ្វើសេវាកម្មគ្រប់ពេលវេលា ។ ក្រុមហ៊ុនត្រូវធ្វើការសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីរបស់ក្រសួង ដើម្បីធ្វើការពិនិត្យបញ្ជីស្នាម និងឯកសារផ្សេងៗ ។ ក្នុងករណីចាំបាច់ក្រសួងមានសិទ្ធិជួលអ្នកឯកទេសផ្នែកគណនេយ្យអោយចូលរួមក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យ និងមានសិទ្ធិថតចំលងនូវឯកសារផ្សេងៗតាមតំរូវការដើម្បីត្រួតពិនិត្យហើយចំពោះការចំណាយលើអ្នកឯកទេសផ្នែកគណនេយ្យនេះជាបន្ទុករបស់ក្រុមហ៊ុន។

**ប្រការ១៨: សេចក្តីជូនដំណឹង**

សេចក្តីជូនដំណឹងណាមួយដែលចេញដោយក្រសួងនិងចេញដោយក្រុមហ៊ុនត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរទៅកាន់អ្នកតំណាងស្របច្បាប់នៃភាគីពាក់ពន្ធ័ដោយៈ (១) ហុចជូនដល់ដៃ (២) រឺតាមប្រៃសណីយ៍ (៣)រឺទូរសារ ។

សេចក្តីជូនដំណឹងនេះចាត់ទុកថាបានទទួលៈ(១) ដោយមានបញ្ជាក់ពេលវេលានៃការទទួលប្រសិនបើផ្តល់អោយដល់ដៃ (២) ចុះហត្ថលេខាទទួលបើជាអនុសិដ្ឋ ។

**ប្រការ១៩:** បទប្បញ្ញត្តិនៃប្រកាស ឬលិខិតបទដ្ឋានទាំងឡាយដែលផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ២០:** អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានពន្ធដារ ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរតនាគារជាតិ ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងគ្រប់នាយកដ្ឋាន និងអង្គភាព ក្រុមហ៊ុន និងបុគ្គលដែល ពាក់ព័ន្ធត្រូវអនុវត្តនិងប្រតិបត្តិតាមខ្លឹមសារនៃប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ២១:** ប្រកាសនេះមានតំលៃអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន:**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ឯកសារ-កាលប្បវត្តិ